សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៧៩៨/០១-១០-២០១០
សាលដីកា
លេខ ៥៤ក្រVI "ញ"/១១-០៧-២០១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
— ❈ —

# តាងនាមប្រជារាស្ត្រខ្មែរ

## សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍

ឆ្នាំពីរពាន់ដប់មួយ ខែកក្កដា ថ្ងៃទីដប់មួយ វេលាម៉ោងប្រាំបីព្រឹក បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ ដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមប្រឹក្សាជំនុំជម្រះ**

១-លោក [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រមប្រឹក្សា

៣-លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៧៩៨ ចុះថ្ងៃទី ០១-១០-២០១០ រវាង :

១.ជនជាប់ចោទឈ្មោះ [redacted] ភេទ ប្រុស ជាតិខ្មែរ អាយុ ៤៣ ឆ្នាំ កើត និងរស់នៅភូមិរកាគយ "ខ" ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម របររកស៊ី កសិករ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ២ នាក់ ទោសពីមុន គ្មាន ។ "ដើមបណ្តឹងឧទ្ធរណ៍"

២.ជនជាប់ចោទឈ្មោះ [redacted] ភេទ ស្រី ជាតិខ្មែរ អាយុ ៣៨ ឆ្នាំ កើត និងរស់នៅភូមិរកាគយ "ខ" ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម របររកស៊ី ធ្វើស្រែ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្តីឈ្មោះ [redacted] មានកូន ២ នាក់ ទោសពីមុន គ្មាន ។ "ដើមបណ្តឹងឧទ្ធរណ៍"

មានមេធាវីការពារ ឈ្មោះ [redacted]

**ត្រូវចោទពីបទ** : បរិហារកេរ្តិ៍ និងជេរប្រមាថ ប្រព្រឹត្តនៅភូមិរកាគយ "ខ" ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី ២០-០៧-២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។



Scanned by CamScanner

46/4

និងដើមបណ្តឹងរដ្ឋប្បវេណី :

១.ឈ្មោះ [redacted] ភេទ ស្រី ជាតិខ្មែរ អាយុ ៤៣ ឆ្នាំ មានទីលំនៅសព្វថ្ងៃ ភូមិរកាគយ "ខ" ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម ។ "ចុងបណ្តឹងឧទ្ធរណ៍"

២.ឈ្មោះ [redacted] ភេទ ស្រី ជាតិខ្មែរ អាយុ ២២ ឆ្នាំ មានទីលំនៅសព្វថ្ងៃ ភូមិរកាគយ "ខ" ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម ។ "ចុងបណ្តឹងឧទ្ធរណ៍"

## ឯរឿងហេតុដូចតទៅ :

តាមពាក្យបណ្តឹងចុះថ្ងៃទី ២១-០៧-២០០៩ របស់ឈ្មោះ[redacted]ថា : កាលពីថ្ងៃទី ២០-០៧-២០០៩ វេលាម៉ោងប្រហែល ៣ : ០០ រសៀល ឈ្មោះ [redacted] បានជេរមកលើកូនរបស់ខ្លួនឈ្មោះ[redacted]ថា មីងញូចដករបងដាក់ចូលដីអញ មីងយកប្តីគេបានកូន ៥ ខែ មីចោរគេចុយ ។ បន្ទាប់មកឈ្មោះ[redacted] បានជេរខ្លួនថា មីព្រាត់ប្រាស់ប្តី មីតែហោង មីដកមបីសដាក់ក្បាលគេ មីងចង់ដកដាក់អ្នកផ្សារដាក់ទៅ និងជេរខ្លួនជាច្រើនទៀត ។

- បានឃើញចម្លើយជនជាប់ចោទឈ្មោះ [redacted]បានឆ្លើយថា : ខ្លួនបានដោតដើមផ្កាតាមព្រំដីមែន តែមិនបានចូលដីខាងគេទេ ដើម្បីកុំឱ្យគោគេចូលក្នុងដីខ្លួន ហើយភាគីឈ្មោះ [redacted]កដកដើមផ្កានេះចោល ។ ក្រោយមកបានប្រកែកគ្នាជាមួយខ្លួន ខ្លួនក៏ជេរទៅ ហើយវាក៏ជេរមកខ្លួនថា មីតែហោងចាំមើលអញសម្លាប់ឯងអស់មួយពូជ គឺឈ្មោះ[redacted]ជាអ្នកជេរទាំងប្អូនថ្លៃ និងប្រពន្ធ ។

- បានឃើញចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថា : ដំបូងខ្លួននៅលើផ្ទះ ស្រាប់តែឮសម្លេងឈ្មោះ[redacted]ជេរប្តីខ្លួន ខ្លួនក៏ចុះមកមើល ស្រាប់តែពេលឃើញខ្លួន ជេរខ្លួនថា : មីយកប្តីគេ ការបាន ៦ ខែកើតកូន ខ្លួនមិនបានជេរតបទេ ព្រោះខ្មាស់គេ ក៏ចូលក្នុងផ្ទះវិញទៅ ។ ដំបូងឈ្មោះ[redacted]មិននៅកន្លែងកើតហេតុទេ ក្រោយមកក៏ឃើញឈ្មោះ [redacted] មកដល់ ហើយក៏ជេរម្តាយខ្លួននូវពាក្យអាក្រក់ៗ តែមិនបានជេរជាមួយខ្លួនទេ ។ សំណូមពរសុំទាមទារជម្ងឺចំនួន ១០.០០០.០០០ រៀល ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៥២ "ង" ចុះថ្ងៃទី ៣១-០៨-២០១០ របស់សាលាដំបូងខេត្តកំពង់ចាម សម្រេចមានខ្លឹមសារដូចខាងក្រោម :

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ :

ក-[redacted]ភេទប្រុស អាយុ ៤៣ ឆ្នាំ ជាតិ ខ្មែរ (សាវតាជាតិដូចខាងលើ) ។

ខ-[redacted]ភេទស្រី អាយុ ៤៣ ឆ្នាំ ជាតិ ខ្មែរ (សាវតាជាតិដូចខាងលើ) ។

ពិន័យជាប្រាក់ក្នុងម្នាក់ចំនួន ១.០០០.០០០៛ (មួយលានរៀល) ពីបទ : បរិហារកេរ្តិ៍ និងជេរប្រមាថ ប្រព្រឹត្តនៅភូមិរកាគយ "ខ" ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី ២០-០៧-២០០៧ តាមមាត្រា ៦៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។



417

Scanned by CamScanner

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] រួមគ្នាសងសំណងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំនួន ២.៥០០.០០០ រៀល (ពីរលានប្រាំសែនរៀល) និងទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំនួន ១.៥០០.០០០ រៀល (មួយលានប្រាំសែនរៀល) ។ ការទាមទារលើសពីនេះ បដិសេធចោល ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ៣១-០៨-២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] និងឈ្មោះ [redacted] ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ៣១-០៨-២០១០ របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ។

-បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ២១-០២-២០១១ របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] (ចូល)
- ជនជាប់ចោទឈ្មោះ [redacted] (ចូល)
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (ចូល)
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (ចូល)
- មេធាវីការពារជនជាប់ចោទ ឈ្មោះ [redacted] (ចូល)

## ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុ

- ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា : ទំនាស់កើតឡើងដោយសារការដកកូនផ្កា ក៏មានការជេរគ្នាទៅវិញទៅមក ខ្លួនក៏មានការប្តឹងតបដែរ ។

- ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា : ពេលឈ្លោះគ្នាចប់ ខ្លួនក៏មកដល់ផ្ទះ ក៏ត្រូវគេជេរ ខ្លួនគ្រាន់តែជាស្រីកម្មង់ដូរប៉ុណ្ណោះ ។ ខ្លួន និងឈ្មោះ [redacted] ត្រូវជាបងប្អូនជីដូនមួយនឹងគ្នា ។

## មហាអយ្យការសន្និដ្ឋាន

ក្រោយពីបានស្តាប់ការដេញដោល ឃើញថា : មានពិរុទ្ធភាពគ្រប់គ្រាន់ សុំតម្កល់ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆ្លើយថា : វាជេរខ្លួនមីព្រាត់ព្រះប្តី មីយកប្តីគេ ពេលនេះខ្លួនសុំឱ្យតុលាការជួយរកយុត្តិធម៌ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆ្លើយថា : ខ្លួនសំណូមពរដូចឈ្មោះ [redacted] ដែរ ។



Scanned by CamScanner

**មេធាវី ពិន ធីតា សន្និដ្ឋាន**

- ការប្តឹងគឺប្តឹងកូនក្តីខ្លួនតែម្នាក់ទេឈ្មោះ [redacted] រីឯការប្តឹងតបរបស់កូនក្តីខ្លួន ព្រះរាជអាជ្ញាពុំបានលើកយកមកពិចារណាទេ ។

- តាមរបាយការណ៍របស់មេភូមិ មេឃុំ និងរបាយការណ៍សំយោគរបស់នគរបាល បាន បញ្ជាក់ថា : ជាការជេរគ្នាទៅវិញទៅមក ។

- ដូចនេះ សុំឱ្យក្រុមប្រឹក្សាសម្រេចបង្វិលសំណុំរឿងនេះទៅតុលាការថ្នាក់ក្រោម សុំឱ្យ ចោទជាថ្មីលើភាគីទាំងសង្ខាង ។

**<u>ក្រុមប្រឹក្សាជំនុំជម្រះថយពិភាក្សា និងប្រកាសសាលដីកា</u>**

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ៣១-០៨-២០១០ របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា : ដោយសារមានទំនាស់ព្រំដី ឈ្មោះ [redacted] និងខ្លួនបានជេរគ្នាទៅវិញទៅមក ខាងឈ្មោះ [redacted] មានទាំងប្អូនថ្លៃ និងប្រពន្ធ បាន ជេរមកខ្លួន ។ រីឯឈ្មោះ [redacted] បានបញ្ជាក់ថា : ពេលជម្លោះចប់ទើបខ្លួនមកដល់ ប៉ុន្តែពុំ បានជេរទេ ។

៣-តាមចម្លើយឈ្មោះ [redacted] ថា : ដំបូងខ្លួននៅលើផ្ទះ ស្រាប់តែឮឈ្មោះ [redacted] ជេរប្តីខ្លួន ពេលខ្លួនចុះមក ឈ្មោះ [redacted] បានជេរខ្លួនទូវពាក្យអាសអាភាសជាច្រើន រួចឃើញ ឈ្មោះ [redacted] មកដល់ ក៏បានជេរម្តាយខ្លួន តែមិនបានជេរខ្លួនទេ ។

៤-តាមការយល់ឃើញខាងលើ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] និងឈ្មោះ [redacted] ពីបទ : ជេរប្រមាថ ប្រព្រឹត្តនៅភូមិរកាគយ "ខ" ឃុំរកាគយ ស្រុកគងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី ២០-០៧-២០០៧ តាមមាត្រា ៦៣ នៃច្បាប់វិសោធនកម្មមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៥-តាមសេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ថា : ការជេរប្រមាថនេះធ្វើទៅវិញទៅ មក ដោយមានការបញ្ជាក់ពីអាជ្ញាធរភូមិ ឃុំ និងមានការប្តឹងទៅព្រះរាជអាជ្ញាទៀតផង ប៉ុន្តែ ករណីនេះតុលាការពុំបានសម្រេចអំពីការជេរទៅវិញទៅមក ហើយដែលសមត្ថកិច្ចសាលាឧទ្ធរណ៍ ពេលនេះជំនុំជម្រះតែទៅលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទលើសាលក្រមតែប៉ុណ្ណោះ ។

៦-រឿងក្តីនេះត្រូវបានសាលាដំបូងខេត្តកំពង់ចាម ធ្វើការអង្កេត និងលើកយកសំអាង ហេតុមកបញ្ជាក់ត្រឹមត្រូវតាមច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដូចនេះ សាលាឧទ្ធរណ៍មិនចាំបាច់លើកយកសំអាងហេតុនេះមកបញ្ជាក់ជាថ្មីទៀតទេ ។



Scanned by CamScanner

៧-សាលក្រមព្រហ្មទណ្ឌលេខ ៩២ "ង" ចុះថ្ងៃទី ៣១-០៨-២០១០ របស់សាលាដំបូងខេត្តកំពង់ចាម សម្រេចមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ហើយ គប្បីតម្កល់ទុកជាបានការតទៅ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ៣១-០៨-២០១០ របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] កជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩២ "ង" ចុះថ្ងៃទី ៣១-០៨-២០១០ របស់សាលាដំបូងខេត្តកំពង់ចាម ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ១១-០៧-២០១១ ចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ទុកសិទ្ធិឱ្យប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- |
| ហត្ថលេខ [redacted] | ហត្ថលេ [redacted] | ហត្ថ [redacted] |

*បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។*

រាជធានីភ្នំពេញ ថ្ងៃទី 02 ខែ 8 ឆ្នាំ ២០១១

ក្រឡាបញ្ជី

បានឃើញ

ប្រធានក្រុមប្រឹក្សា

[redacted]